# សេចក្តីអត្ថាធិប្បាយ និងអនុសាសន៍: អំពីសេចក្តីព្រាងច្បាប់ស្តីពីពន្ធនាគារ

របាយការណ៍សង្ខេប លីកាដូ

ខែតុលា ឆ្នាំ២០១១

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

L I C A D H O

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួជាអ្នកតស៊ូមតិ សម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈ កម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខា ទូទាំង១២ ខេត្ត-ក្រុងផ្សេងទៀត។

**អង្គការលីកាដូអនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរ:**
**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស:**

- **ឃ្លាំមើលការរំលោភសិទ្ធិមនស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋលើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈ ការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:** ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗ ទទួលបាននូវកិច្ចការពារផ្នែកច្បាប់ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារ:** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារ ចំនួន១៨ ដើម្បីធ្វើការវាយតម្លៃ អំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថា ជនជាប់ឃុំទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវេជ្ជសាស្ត្រ:** ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារចំនួន ១២ កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ទៅកាន់មន្ទីរពេទ្យ។
- **សេវាកម្មសង្គមកិច្ច:** ក្រុមការងារធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយសម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណជន អំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារបង្កើតបណ្ដាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឲ្យមានការផ្លាស់ប្តូរសង្គម និងច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេតដោយលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ
អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦
អ៊ីម៉ែល: contact@licadho-cambodia.org
គេហទំព័រ: http://www.licadho-cambodia.org

# មាតិកា


សេចក្តីសង្ខេប ១

ការវិភាគ៖ មាត្រាសំខាន់ៗ នៃសេចក្តីព្រាងច្បាប់ស្តីពីពន្ធនាគារ ៤

មាត្រា ២៨ ៤

មាត្រា ៤១ ៥

មាត្រា ៤៩ ៥

មាត្រា ៥២ ៧

មាត្រា ៥៦ ៩

មាត្រា ៥៩ ១០

មាត្រា ៧១ ១១


□□□

# សេចក្តីសង្ខេប

រដ្ឋសភាជាតិកម្ពុជា កំពុងរៀបចំបោះឆ្នោតអនុម័តច្បាប់ស្តីពីពន្ធនាគារ ដែលជាច្បាប់គោលមួយនៃបទដ្ឋានគតិយុត្តិដែលទាក់ទង និងប្រព័ន្ធពន្ធនាគារនៅព្រះរាជាណាចក្រកម្ពុជា[១]។ ដោយយេហតុថា ក្នុងមួយរយៈកាលកន្លងមកនេះ ពន្ធនាគារនៃប្រទេសកម្ពុជាបាន ដាក់អោយដំណើរការ ដោយពុំទាន់មានច្បាប់ពន្ធនាគារនៅឡើយទេ តែត្រូវបានអនុត្ត និងគ្រប់គ្រងដោយប្រកាសអនុក្រិត្យ និងបទបញ្ញាផ្ទៃក្នុងមួយចំនួនដែលមានស្រាប់។

គោលបំណងដែលបានលើកឡើងក្នុងច្បាប់នេះគឺ (ទី១) កំណត់អំពីការគ្រប់គ្រងពន្ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ និង (ទី២) "ដើម្បីផ្តល់ការអប់រំ កែប្រែស្តារនីតិ-សម្បទា ដើម្បីធ្វើសមាហរណកម្មជនជាប់ឃុំទៅក្នុងសង្គមជាតិវិញ។ គ្រប់គ្រងជនជាប់ឃុំឲ្យធានាបានសន្តិសុខ សុវត្ថិភាព សុខភាព និងមនុស្សធម៌ ស្របតាមគោលការណ៍អន្តជាតិ និងវិធានសហប្រជាជាតិ សម្រាប់ការពារអនីតិជនដែលត្រូវបានដកហូត សិទ្ធិសេរីភាព។"[២]។

លីកាដូ បានធ្វើការកត់សំគាល់ លើសេចក្តីព្រាងច្បាប់នេះថា វាជាការបោះជំហានមួយជាវិជ្ជមាន ដើម្បីឆ្ពោះទៅរកស្ថេរភាព និងការអនុវត្តច្បាប់ នៃប្រព័ន្ធគ្រប់គ្រងពន្ធនាគារ របស់កម្ពុជា។ ជាមួយគ្នានេះផងដែរ លីកាដូបានពិនិត្យឃើញថា ច្បាប់នេះមានការខ្វះខាតផ្នែកសំខាន់ៗមួយចំនួន។ នៅក្នុងរបាយការណ៍នេះ នឹងបង្ហាញនូវកង្វល់ ដែលគួរឲ្យព្រួយបារម្ភបំផុតរបស់អង្គការលីកាដូ ដើម្បីផ្តល់ជូនជាជំនួយស្មារតី ដល់អ្នកដែលពាក់ព័ន្ធមួយចំនួន ក្នុងវិសយ័នេះ ជាពិសេសសម្រាប់រដ្ឋសភាជាតិ ក្នុងការយកច្បាប់នេះទៅពិភាក្សានៅក្នុងខែនេះ។

នៅក្នុងសេចក្តីពង្រាងច្បាប់នេះ មានការវិវឌ្ឍន៍ វិជ្ជមានមួយចំនួនដែលទាក់ទងនឹងការការពារសិទ្ធិដល់ជនជាប់ឃុំ ប៉ុន្តែមិនបានពន្យល់លម្អិតអំពីសិទ្ធិទាំងនេះឡើយ។ ភាពស្រពិចស្រពិលនៃច្បាប់ គឺនៅតែនៅល់ជាបញ្ហាដដែល។ ឧទាហរណ៍ ការមិនកំណត់នូវខ្នាតគំរូណាមួយ ឬ បទដ្ឋានជាអប្បបរមាក្នុងផ្នែកមួយចំនួន ដូចជា អនាម័យ នីតិវិធីនៃការដាក់វិន័យ ទំហំនៃបន្ទប់ឃុំឃាំង និងការឲ្យចេញក្រៅបន្ទប់ដើម្បីលំហែកាយ ដែលបញ្ហាទាំងអស់នេះ គ្រាន់តែកំណត់នូវនៅក្នុងសេចក្តីព្រាងច្បាប់ថា "ត្រូវតែមានភាពគ្រប់គ្រាន់"។ ភាពចន្លោះនៃសេចក្តីព្រាងផងដែលនោះគឺ ការខកខានមិនបានកំណត់នូវយន្តការ ការពារដ៏មាន ប្រសិទ្ធិភាពចំពោះករណីមួយចំនួនដូចជា ការដាក់វិន័យចំពោះអ្នកជាប់ឃុំ និងកិច្ចការពារ ពិសេសចំពោះអ្នកជាប់

[១] អគ្គនាយកដ្ឋានពន្ធនាគារនាពេលបច្ចុប្បន្នកំពុងប្រតិបត្តិការ ២៦ ពន្ធនាគារ នៃប្រទេសកម្ពុជា រួមទាំងអាគារទើបបើកថ្មីនៅខេត្តប៉ៃលិន។ អង្គការលីកាដូ ឃ្លាំមើល ១៨ ពន្ធនាគារក្នុងចំណោមពន្ធនាគារទាំងនោះ រួមទាំងពន្ធនាគារយោធានៅទួលស្លែង ដែលអគ្គនាយកដ្ឋានពន្ធនាគារមិនធ្វើប្រតិបត្តិការ។

[២] ពង្រាងច្បាប់ស្តីពីពន្ធនាគារ មាត្រាទី ១ និង២

ឃុំណា ដែលបានដាក់បណ្តឹងតវ៉ានូវអំពើរំលោភបំពានរបស់ជនជាប់ឃុំដូចគ្នា ឬ អំពើរំលោភរបស់មន្ត្រីពន្ធនាគារ។

លីកាដូមានជំនឿថា និតិកម្មច្បាប់ដែលមានសារៈសំខាន់ ត្រូវតែមានបទដ្ឋាន ជាអប្បបរមាជាគន្លឹះ ហើយលីកាដូសូមផ្តល់អនុសាសន៍ ច្បាប់នេះគួរតែមានការកែប្រែឡើងវិញ។ ជាជម្រើសល្អ ច្បាប់នេះគួរស្រង់យកខ្លឹមសារល្អៗមួយចំនួនដែលមានកំណត់នៅក្នុងបទបញ្ញត្តិបទដ្ឋានជាអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោស (UNSMR) របស់អង្គការសហប្រជាជាតិ ឲ្យបានអតិបរមា តាមដែលអាចធ្វើទៅបាន។

ប្រសិនបើសេចក្តីព្រាងច្បាប់នេះបានអនុម័តនិងប្រកាសឲ្យចូលជាធរមាន ដោយពុំមានការកែប្រែទេនោះ នោះជាការជៀសមិនផុតឡើយ ដែលគេត្រូវសរសេរលិខិតបទដ្ឋានមួយចំនួនបន្ថែមពីលើច្បាប់នេះទៀត ដើម្បីបញ្ជាក់ឲ្យបានច្បាស់ពីផ្នែកខ្លះដែលមានលក្ខណៈមិនច្បាស់លាស់ដូចបានលើកឡើងខាងដើម។ លីកាដូសូមអំពាវនាវដល់ ក្រសួងមហាផ្ទៃ និង អគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីពិនិត្យដោយយកចិត្តទុកដាក់ ចំពោះការស្នើសុំ ដែលកើតចេញពីអង្គការសង្គមស៊ីវិល អំពីលិខិតបទដ្ឋានបន្ទាប់បន្សំផ្សេងទៀត។

សេចក្តីព្រាងច្បាប់នេះ មិនបាននិយាយលើបញ្ហាជាចំបងៗមួយចំនួន ដែលត្រូវគេបានចងក្រងជាឯកសារយ៉ាងច្បាស់លាស់ ក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកដូចជា៖ (ទី១) ការទាយកប្រាក់ ឬការតម្រូវឲ្យបង់ប្រាក់ពីមន្ត្រីពន្ធនាគារ ចំពោះអ្នកចូលជួបសួរសុខទុក្ខ ដែលជាមិត្តភ័ក្តិ និងសាច់ញាតិរបស់អ្នកជាប់ឃុំ (ទី២) និងការទាយកប្រាក់ដែលមិនអាចលុបបំបាត់បាន ពីសេវាកម្មដែលមានជាមូលដ្ឋានរបស់អង្គភាពពន្ធនាគារដូចជា ពីការផ្តល់ទឹកស្អាត ឬ ទំហំនៃកន្លែងស្នាក់នៅ។

លីកាដូមានជំនឿថា ច្បាប់នេះគួរតែមានការកែប្រែ ដើម្បីហាមឃាត់ការបង់ប្រាក់ ដោយខុសច្បាប់ចំពោះការចូលជួបសួរសុខទុក្ខ អ្នកជាទីស្រលាញ់នៃជនជាប់ឃុំ និងសេវាកម្មផ្តល់ជូនជាមូលដ្ឋានរបស់ពន្ធនាគារដូចដែលបានលើកឡើងមកនេះ។

សេចក្តីព្រាងច្បាប់នេះបានដាក់បញ្ចូលតិចតួចណាស់ ក្នុងការបញ្ជាក់លើបញ្ហាចង្អៀតណែនដែលមិនអាចគ្រប់គ្រងបាន។ ទោះបីជាបញ្ហានេះត្រូវបានមើលឃើញថាប្រព័ន្ធពន្ធនាគារមិនមានអំណាចក្នុងការសំរេចនៃការឃុំខ្លួន ឬ ដោះលែងជនជាប់ឃុំឡើយ។ ចំនុចនេះ ក៏ផ្នែកមួយនៃផលប៉ះពាល់អវិជ្ជមាន ដែលជាហេតុនាំឲ្យភាពចង្អៀតណែនខ្លាំងនៃពន្ធនាគារកម្ពុជាកាន់តែយ៉ាប់ខ្លាំងឡើងៗ។ មាត្រា៥២ បានដកចេញដោយស្វ័យប្រវត្តចំពោះជនជាប់ណាដែលប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុង ដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ពន្ធនាគារ មិនត្រូវលើក

យកមកពិនិត្យលក្ខណៈវិនិច្ឆ័យ សម្រាប់ការបន្ធូរបន្ថយទោស និងលើកលែង ទោសក្នុងរយៈពេលមួយឆ្នាំ។

នេះមិនមែនមានន័យថា សេចក្តីព្រាងច្បាប់នេះអវិជ្ជមានទាំងស្រុងនោះទេ។ វាមាន ខចែងមួយចំនួនដែលការពារសិទ្ធិជនជាប់ឃុំ និងសម្រួលដល់ប្រព័ន្ធគ្រប់គ្រងពន្ធនាគារ បើអនុវត្តបានត្រឹមត្រូវនិងមានវិជ្ជាជីវៈ។ ឧទាហរណ៍ មាត្រា៨១ ហាមដាច់ខាត ការធ្វើទារុណកម្ម អំពើឃោរឃៅ និងរាល់ទម្រង់ផ្សេងទៀតនៃការរំលោភបំពាន ដែលប្រព្រឹត្តទៅលើជនជាប់ឃុំ ត្រូវផ្តន្ទាទោស ដោយយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះ មាត្រា ៨៣ អំពើរបស់មន្ត្រីពន្ធនាគារ ដែលទទួលឃុំបុគ្គលណាម្នាក់ ឬពន្យាពេលឃុំ ឬ ដោះលែងជនជាប់ឃុំដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ អំពើដូចការរៀបរាប់ខាងលើនេះគេច្រើនឃើញកើតមាន ជាធម្មតាសម្រាប់ពន្ធនាគារខ្លះក្នុងប្រទេសកម្ពុជា ដើម្បីជាមធ្យោបាយទាយកប្រាក់ពីជនជាប់ឃុំមុននឹងដោះលែង។ មាត្រាផ្សេងទៀតហាមឃាត់មិនឲ្យដាក់ទណ្ឌលើរាងកាយ ការដាក់ជនជាប់ឃុំនៅក្នុងបន្ទប់ងងឹត ហើយនិងការប្រើឲ្យជនជាប់ឃុំ ដាក់ទណ្ឌកម្មទៅលើជនជាប់ឃុំ ដូចគ្នា។

សារៈសំខាន់មាត្រា១០ នៃសេចក្តីព្រាច្បាប់ថ្មីនេះ អនុញ្ញាតអោយក្រសួងមហាផ្ទៃចេញប្រកាស ដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារកម្ពុជាជាលក្ខណៈបទដ្ឋានអប្បបរមា។ នៅខណៈដែលប្រព័ន្ធនាគារកម្ពុជាសព្វថ្ងៃ ពុំទាន់មានបទបដ្ឋានអប្បបរមាច្បាស់លាស់នៅឡើយ។

ខាងក្រោមនេះ គឺជាការវិភាគនូវចំនុចមួយចំនួន នៃមាត្រាសំខាន់ៗដែលបានដកស្រង់ចេញពីសេចក្តីព្រាងច្បាប់ ជាមួយនឹងការផ្តល់យោបល់ដើម្បីកែលំអ។ មាត្រានៃសេចក្តីព្រាងច្បាប់ដែលបានជ្រើសរើសនេះ ត្រូវបានផ្តល់ជាសំគាល់រំលេចដោយជាអក្សរទ្រេត។

□□□

# ការវិភាគៈ មាត្រាសំខាន់ៗ នៃសេចក្ដីព្រាងច្បាប់ស្ដីពីពន្ធនាគារ

## មាត្រា ២៨

*ជនជាប់ឃុំ មានសិទ្ធិប្ដឹងតវ៉ាទៅប្រធានពន្ធនាគារ ឬទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ឬព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពីអំពើរំលោភរបស់ជនជាប់ឃុំដូចគ្នា ឬអំពើរំលោភរបស់មន្ត្រីពន្ធនាគារ។*

*ពាក្យបណ្ដឹងតវ៉ារបស់ជនជាប់ឃុំ ត្រូវធ្វើឡើងតាមរយៈមន្ត្រីពន្ធនាគារ ឬអ្នកសួរសុខទុក្ខ ការ ឬ អ្នកសួរសុខទុក្ខសាច់ញាតិ ឬ មេធាវីរបស់ជនជាប់ឃុំ ឬ តំណាងអង្គការអយ្យការ។ គ្មានជនជាប់ឃុំណាម្នាក់ត្រូវបានដាក់ទណ្ឌកម្ម ឬ ត្រូវបានរើសអើងដោយសារតែបានដាក់ពាក្យបណ្ដឹង ឬ ការដាក់ពាក្យស្នើសុំនោះឡើយ។*

➢ **សេចក្ដីអត្ថាធិប្បាយ:** ជនជាប់ឃុំដែលប្ដឹងពីស្ថានភាពពន្ធនាគារ ឬការរំលោភបំពាន គឺជាអ្នកដែលងាយរងគ្រោះជាងគេបំផុតក្នុងចំណោមជនជាប់ឃុំទាំងអស់។ ការលើកឡើង អំពីការប្ដឹងតវ៉ាទាំងនោះ តាមការអនុវត្តជាក់ស្ដែង ជនជាប់ឃុំត្រូវបង្ហាញអំពីភស្តុតាងដោយខ្លួនឯង ខណៈដែលជនជាប់ឃុំទាំងនោះ កំពុងរស់នៅជាមួយនិងក្រោមការគ្រប់គ្រង ជនដែលពួកគេកំពុងប្ដឹងតវ៉ា (ជនសង្ស័យ)។ ម្យ៉ាងវិញទៀត កន្លែងជួបប្រាស្រ័យទាក់ទងរបស់ជនជាប់ឃុំក៏មានការត្រួតពិនិត្យ និងឃ្លាំមើលយ៉ាងតឹងរឹង។ នេះជាហេតុអាចនាំឲ្យមានគំនុំគំគួន ការសងសឹក ឬ បណ្ដឹងតវ៉ារបស់អ្នកជាប់ឃុំទាំងនោះត្រូវបានផ្អិបចោល។

ហេតុដូច្នេះ យន្តការនៃការដាក់ពាក្យបណ្ដឹងតវ៉ាប្រកបដោយប្រសិទ្ធិភាព ត្រូវតែផ្ដល់យន្តការច្រើន ដែលការពារជនជាប់ឃុំទាំងឡាយណាដែលស្នើរសុំប្ដឹងតវ៉ា។ ឧទាហរណ៍ យន្តការបែបនេះ គួរតែបញ្ចូលលទ្ធភាព ដើម្បីអាចដាក់បណ្ដឹងតវ៉ាដល់អាជ្ញាធរមានសមត្ថកិច្ចក្រៅពន្ធនាគារ (ក្រុមអធិការកិច្ចពន្ធនាគារ ដែលឃ្លាំមើលនីតិវិធី និងលទ្ធភាពក្នុងការបន្តប្ដឹងទៅអាជ្ញាធរថ្នាក់ខ្ពស់ បើពួកគេមិនពេញចិត្តនឹងការឆ្លើយតបដែលខ្លួនទទួលបានពីថ្នាក់ក្រោម។ មាត្រា ២៨ ខ្វះចន្លោះខចែងនេះ បើទោះមានលទ្ធភាពប្ដឹងតាមរយៈសាច់ញាតិ អ្នកចូលជួបសួរសុខទុក្ខ មេធាវី ឬតំណាងអង្គការអយ្យការពីដំបូងក៏ដោយ។

➢ **អនុសាសន៍:** ច្បាប់នេះគួរតែមានការកែប្រែ ដោយរួមបញ្ចូលការការពារជាគន្លឹះសម្រាប់ជនជាប់ឃុំ ដែលដាក់ពាក្យបណ្ដឹង រួមទាំងនីតិវិធីនៃការដាក់ពាក្យប្ដឹង នីតិវិធីនៃការប្ដឹងបន្ត និងយន្តការរារាំងមិនឲ្យមានការសងសឹក គំនុំគំគួន។ ច្បាប់នេះក៏គួរតែតម្រូវ ឲ្យមានការអនុម័តបទបញ្ជាផ្ទៃក្នុងបន្ទាប់បន្សំ លម្អិតពីខចែង ដែលនាំទៅរកប្រព័ន្ធគ្រប់គ្រងពន្ធនាគារមួយ ដែល

អាចប្តឹងតវ៉ាបាន ដូចជាជាក់ស្តែងនៃការដាក់ពាក្យបណ្តឹងបឋមភាពសំងាត់នៃការទទួលបណ្តឹង ដោយផ្ទាល់មាត់។ល។

ដើម្បីអោយមាត្រានេះអាចអនុវត្តកើត ចំពោះបណ្តឹងដែលបង្ករអោយមានគ្រោះថ្នាក់ ដល់ជនរងគ្រោះ រដ្ឋសភាជាតិគួរតែពិចារណាលើការកែប្រែ ដោយតម្រូវឲ្យត្រួតពិនិត្យឡើង វិញនូវសេចក្តីព្រាងច្បាប់នេះ។ សេចក្តីព្រាងច្បាប់នេះយ៉ាងហោចណាស់ ត្រូវធ្វើឡើងដោយ ស្ថាប័នឯករាជ្យមួយដូចជា ការបង្កើតក្រុមឯករាជ្យពិសេសដោយមានមន្ត្រីរដ្ឋាភិបាលមកពី ក្រសួងពាក់ព័ន្ធផ្សេងទៀតៗ ព្រមទាំងមានកិច្ចសហការចូលរួមពីមន្ត្រីឃ្លាំមើលពន្ធនាគារ នៃ អង្គការមិនមែនរដ្ឋាភិបាល។

## មាត្រា ៤១

*កូនតាមម្តាយ ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅក្នុងពន្ធនាគារជាមួយម្តាយ ត្រឹមអាយុក្រោម ៣ឆ្នាំ និងត្រូវបានផ្តល់ម្ហូបអាហារ សម្លៀកបំពាក់ និងសេវាថែទាំសុខភាព។ កូនតាមម្តាយ ដែលមានអាយុចាប់ពី ០៣ឆ្នាំឡើង បើគ្មានអាណាព្យាបាលទទួលខុសត្រូវ ការចិញ្ចឹមបីបាច់ថែ រក្សាបន្តនៅខាងក្រៅ ជាបន្ទុករបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។*

➢ **សេចក្តីអត្ថាធិប្បាយ:** បទបញ្ញត្តិដែលកំពុងតែអនុវត្តពេលបច្ចុប្បន្ន បានអនុញ្ញាតិឲ្យកូន ស្នាក់នៅក្នុងពន្ធនាគារជាមួយឪពុក ឬ ម្តាយរហូតដល់អាយុប្រាំមួយឆ្នាំ។ វាមិនច្បាស់លាស់ថា ហេតុអ្វីបានជាអាយុត្រូវបន្ទាបនៅត្រឹមបីឆ្នាំ ចំនុចនេះវានឹងអាចធ្វើឲ្យកើនឡើង ចំនួន "ក្មេង កំព្រាពីបុព្វហេតុដែលឪពុកឬម្តាយជាប់ពន្ធនាគារ"។ នៅត្រង់ចំនុចនេះ លីកាដូបានកត់សម្គាល់ ឃើញមានការកើនឡើងនៃការចាប់ និងការឃុំខ្លួន ដែលមានកើតឡើងជារឿយៗ លើអ្នកទទួល បន្ទុកគ្រួសារទាំងមូល នេះមានន័យថាពុំមានអ្នកមើលថែរក្សាកូននៅខាងក្រៅពន្ធនាគារ ឡើយ។

➢ **អនុសាសន៍:** ច្បាប់នេះគួរតែមានការកែប្រែ ដោយអនុញ្ញាតិឲ្យកូនអាចស្នាក់នៅជាមួយ ឪពុកម្តាយ របស់ពួកគេក្នុងពន្ធនាគាររហូតដល់អាយុប្រាំមួយឆ្នាំ។

## មាត្រា ៤៩

*ប្រធានពន្ធនាគារ អាចប្រើប្រាស់កម្លាំងប្រតិបត្តិការ ដើម្បីរក្សាសន្តិសុខ សុវត្ថិភាព ពន្ធនាគារ។ ក្នុងករណីធ្ងន់ធ្ងរ ប្រធានពន្ធនាគារត្រូវរាយការណ៍សុំកម្លាំងអន្តរាគមន៍ទៅគណ: បញ្ជាការឯកភាពរដ្ឋបាល រាជធានី ខេត្ត។*

➢ **សេចក្តីអត្ថាធិប្បាយ:** មាត្រានេះ បានពង្រីកវិសាលភាពនៃការប្រើប្រាស់កំលាំង និងមានលក្ខណៈស្រពិចស្រពិល ដោយពុំបានដាក់ការរឹតបន្តឹងឲ្យបានគ្រប់គ្រាន់ណាមួយ ក្នុងការប្រើប្រាស់កម្លាំងអន្តរាគមន៍។ ឧទាហរណ៍ ការប្រើប្រាស់កម្លាំង ជាគោលការណ៍ចាំបាច់ត្រូវតែសមាមាត្រទៅនឹងការគម្រាមកំហែង។ កាលៈទេសៈដែលតម្រូវឲ្យប្រើប្រាស់កម្លាំង "ភ្លាមៗ" ត្រូវតែបកស្រាយអោយបានតឹងរឹង។ លើសជាងនេះទៀត ការដែលកំណត់ឲ្យ "កម្លាំងប្រដាប់អាវុធ" ពាក់ពន្ធ័និងកិច្ចការពន្ធនាគារ គឺជាការមួយដែលត្រូវចារណាអោយ បានស៊ីជំរៅផងដែរ ជាពិសេសការប្រប្រាស់កម្លាំងអន្តរាគមន៍របស់រាជធានី ឬ ខេត្ត ដែលរួមទាំងកងរាជអាវុធហត្ថផងដែរ។ ការប្រើប្រាស់កម្លាំងប្រដាប់អាវុធ ដើម្បីដោះស្រាយនូវភាព ចលាចលក្នុងពន្ធនាគារ វាជាជំរើសដែលតំរូវឲ្យមានការពិចារណាយ៉ាងច្បាស់លាស់ពីគ្រប់បញ្ហា ដែលបានចោទឡើង អំពីផលប៉ះពាល់ជាអវិជ្ជមានទាំងឡាយ។

គេមិនចាំបាច់ក្នុងការការសរសេរលំអិត ដែលមានកំរិតជាអប្បបរមា ដូចជានៅក្នុង អនុក្រិត្យ ប្រកាស ឬ គោលនយោបាយ ពីការប្រើប្រាស់កម្លាំងប្រដាប់អាវុធនោះទេ។ ហើយ បញ្ហានេះ ក៏មិនកំណត់ជាក់លាក់ជាកំរិតអប្បបរមា សំរាប់ការគ្រប់គ្រងនៃប្រព័ន្ធពន្ធនាគាទូទាំងពិភពលោកឡើយ

➢ **អនុសាសន៍:** សេចក្តីព្រាងច្បាប់នេះគួរតែតម្រូវ ក្នុងការប្រើសប្រាស់កម្លាំង ត្រូវអោយសមាមាត្រទៅនឹងការគម្រាមកំហែង ដូចដែលបានលើកឡើងខាងលើ។ ដោយមានការអធិប្បាយដើម្បីកំណត់ អំពីការប្រើប្រាស់កម្លាំងប្រដាប់អាវុធក្នុងពន្ធនាគារ។ ដែលការ កំណត់ទាំងនោះគួរតែពិចារណានូវចំនុចសំខាន់ៗដូចខាងក្រោមៈ

- ត្រូវឲ្យប្រាកដច្បាស់ថា កម្លាំងប្រដាប់អាវុធមិនត្រូវបានប្រើប្រាស់ ជាវិធានការក្នុងការដាក់ទណ្ឌកម្ម ហើយវាក៏មិនមែនជាវិធានការវិន័យដែរ។
- បញ្ជាក់ថា មន្ត្រីពន្ធនាគារអាចប្រើប្រាស់កម្លាំងប្រឆាំងនឹងជនជាប់ឃុំ ក្នុងករណីដែលមិនអាចដោះស្រាយស្ថានការណ៍នោះបាន។ មន្ត្រីទទួលបន្ទុកគួរស្វះស្វែងរកការសហការ ពីជនជាប់ឃុំណាដែលស្ម័គ្រចិត្ត មុននឹងសម្រេចប្រើប្រាស់កម្លាំង។
- អនុញ្ញាតិឲ្យប្រើប្រាស់កម្លាំងតែចំពោះស្ថានភាពជាក់លាក់ប៉ុណ្ណោះ ឧទាហរណ៍ នៅពេលដែលចាំបាច់ ក្នុងការគ្រប់គ្រងលើជនជាប់ឃុំ ដើម្បីការពារ និងធានាសុវត្ថិភាពរាងកាយរបស់ជនជាប់ឃុំ មន្ត្រីពន្ធនាគារ និងបុគ្គលផ្សេងទៀត ដើម្បីរារាំងមិនឲ្យមានការខាតបង់ទ្រព្យសម្បត្តិធ្ងន់ធ្ងរ និងធានាសន្តិសុខក្នុងស្ថាប័ន និងសណ្តាប់ធ្នាប់។
- តម្រូវឲ្យមន្ត្រីពន្ធនាគារទទួលនូវវគ្គបណ្តុះបណ្តាលពិសេស ដើម្បីជំរុញឲ្យពួកគេចេះអត់ធ្មត់ ចំពោះជនជាប់ឃុំដែលមិនសូវស្តាប់បង្គាប់។

- ត្រូវឲ្យប្រាកដច្បាស់ថា លើកលែងតែកាលៈទេសៈពិសេស មិនគួរអោយមន្ត្រីពន្ធនាគារមានអាវុធជាប់នឹងខ្លួនទេ នៅដែលបំពេញតួនាទីប្រាស្រ័យទាក់ទងផ្ទាល់ ជាមួយនឹងជនជាប់ឃុំ។
- មន្ត្រីពន្ធនាដែលអាចប្រើប្រាស់អាវុធបាន គឺជាមន្ត្រីរូបណាដែលបានឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវអំពីបញ្ហានេះ។
- បង្ហាញឲ្យច្បាស់រវាងស្ថានភាពដែលតម្រូវឲ្យប្រើប្រាស់កម្លាំង "ភ្លាមៗ" និង "បម្រុង" ព្រមទាំង ដាក់ចេញនូវសេចក្តីអធិប្បាយផ្សេងៗដើម្បីពន្យល់។

រាជរដ្ឋាភិបាល គួរពិចារណាលើខ្លឹមសារ នៃបទបញ្ញត្តិដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោស របស់អង្គការសហប្រជាជាតិ មាត្រា ៥៤។

## មាត្រា ៥២

*ជនជាប់ឃុំ ដែលបានប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុង ដែលធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់ពន្ធនាគារ មិនត្រូវលើកយកមកពិនិត្យលក្ខណៈវិនិច្ឆ័យសម្រាប់ការបន្ធូរបន្ថយទោស និងលើកលែងទោសក្នុងរយៈពេលមួយឆ្នាំ។ ក្នុងករណីមិនរាងចាលត្រូវឃុំខ្លួន នៅក្នុងបន្ទប់ដោយឡែក។*

*ប្រធានពន្ធនាគារ ដែលចេញបទបញ្ជាឲ្យឃុំខ្លួននៅក្នុងបន្ទប់ដោយឡែក ត្រូវបញ្ជាក់ ពីមូលហេតុ និងត្រូវរាយការណ៍ភ្លាមមកអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ។*

*បទបញ្ជាឃុំខ្លួនដោយឡែកអាចមានរយៈពេលពី១៤ (ដប់បួន) ថ្ងៃដល់ ២០ (ម្ភៃ) ថ្ងៃ។ ក្នុងករណីមិនរាងចាល បទបញ្ជានេះអាចត្រូវបានចេញបន្តទៀត។*

*ក្នុងរយៈពេលនៃការរងទណ្ឌកម្មដោយត្រូវឃុំខ្លួនក្នុងបន្ទប់ដោយឡែក ជនជាប់ឃុំមិនត្រូវបានអនុញ្ញាតឲ្យជួបគ្រួសារសាច់ញាតិដែលមកសួរសុខទុក្ខ ចូលរួមសកម្មភាពផ្សេងៗ ក្នុងពន្ធនាគារ។*

➢ **សេចក្តីអត្ថាធិប្បាយ:** មាត្រា ៥២ អាចកត់សម្គាល់ឃើញថា ចរិកលក្ខណៈពុំច្បាស់លាស់នៅក្នុងច្បាប់នៅមានភាពស្រពិចស្រពិលយ៉ាងខ្លាំង និងដែលមិនអាចអោយអនុវត្តកើតឡើយ។ ខចែងនេះ ក៏ធ្ងន់ធ្ងរជ្រុលហួសហេតុដែរ។ មាត្រា ៥២ តម្រូវឲ្យឃុំខ្លួនក្នុង"បន្ទប់ដោយឡែក"[៣] ក្នុងករណីមិនរាងចាល ការប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុង ដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់

[៣] សរុបមក ឃ្លានេះសំដៅលើការបង្ខាំងទុកតែឯង ប៉ុន្តែទណ្ឌកម្មនេះលំបាកនៅក្នុងប្រទេសកម្ពុជាដោយសារភាពចង្អៀតណែនដែល មិនអាចគ្រប់គ្រងបាន។ ជាក់ស្តែង បន្ទប់ឃុំឃាំងដោយឡែក អាចជាបន្ទប់ដាក់ទណ្ឌកម្មដែលមានភាពចង្អៀតណែន ដែលមានស្ថានភាពអាក្រក់ជាកន្លែងដែលជនជាប់ឃុំទទួលបានការអនុញ្ញាតិឲ្យចេញក្រៅសម្រាប់ពេលជាក់លាក់ណាមួយ

ផ្ទាប់ពន្ធនាគារ។ ច្បាប់នេះ បានដាក់កម្រិតលើគ្រប់ការល្មើសនឹងបទបញ្ជាផ្ទៃក្នុង វាពុំមានចែង អំពីប្រភេទល្មើសណាស់មួយជាក់លាក់ឡើយ។ សរុបមក គេអាចអនុវត្តទៅលើជនជាប់ឃុំក្នុង ការល្មើស និងបញ្ជាផ្ទៃក្នុងណាមួយក៏បាន ដោយគិតចាប់ពីការមិនសម្អាតបន្ទប់ឃុំឃាំង រហូត ដល់ការនាំចូលកាសែតអាន ដោយគ្មានការអនុញ្ញាត។

មាត្រា ៥២ ក៏បានដកចេញជនជាប់ឃុំទាំងអស់ដែលបានប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃ ក្នុង ដែលធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់ពន្ធនាគារ មិនត្រូវលើកយកមកពិនិត្យ លក្ខណៈវិនិច្ឆ័យ សម្រាប់ការបន្ធូរបន្ថយទោស និងលើកលែងទោសក្នុងរយៈពេលមួយឆ្នាំ។ ក្នុងស្ថានភាពដែលចំនួនអ្នកទោសចេះតែកើនឡើងយ៉ាងដូចនេះ លីកាដូទទួលស្គាល់ថា រដ្ឋបាលពន្ធនាគារ ត្រូវការអនុវត្តបទបញ្ជាផ្ទៃក្នុងជាការចាំបាច់ ដើម្បីគ្រប់អ្នកជាប់ឃុំក្នុង ពន្ធនាគារ។ ការមិនលើកយកមកពិនិត្យលក្ខណៈវិនិច្ឆ័យ ក្នុងការងារបន្ធូរបន្ថយទោស និង លើកលែងទោស ចំពោះការល្មើសនឹងបទបញ្ជាផ្ទៃក្នុង ដោយមិនមានកំណត់ប្រភេទល្មើសជាក់ លាក់ គឺជាកិច្ចការមួយដែលមិនអាចធ្វើបានឡើយ។

ដោយហេតុថា ស្ថានភាពពន្ធនាគារនៃប្រទេសកម្ពុជាថ្មីៗនេះ មានការកើនឡើងអ្នកជាប់ ឃុំនូវចំនួនប្រមាណជិតពីរដង នៃសមត្ថភាពផ្ទុករបស់របស់ពន្ធនាគារ។ ដូចនេះ ជំរើសនៃការ ប្រើប្រាស់ឪកាស ដើម្បីបន្ធូរបន្ថយទោសជនជាប់ឃុំ ក៏ជាមធ្យោបាយគួរពិចារណាដើម្បីដោះ ស្រាយចំនួនកើនឡើងច្រើនលើសលប់នៃអ្នកទោស។

ខ្លឹមសារវិជ្ជមាននៃច្បាប់នេះ មិនបានផ្តល់ជម្រើសឲ្យរដ្ឋបាលពន្ធនាគារក្នុងការគ្រប់គ្រង លើបទបញ្ជាផ្ទៃក្នុងទេ។ វាបញ្ជាក់ថា ការមិនរាងចាលត្រូវតែជាប់ឃុំក្នុងបន្ទប់ដាច់ដោយឡែក។ សម្រាប់ទស្សនៈសិទ្ធិមនុស្ស ច្បាប់នេះមិនគ្រាន់តែមិនសមស្របប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង បង្ហាញឲ្យឃើញយ៉ាងច្បាស់ អំពីយុទ្ធសាស្ត្រខ្សោយមួយសម្រាប់ការគ្រប់គ្រងពន្ធនាគារ។ លើសជាងនេះទៀត ការដាក់ឲ្យនៅដោយឡែករយៈពេលអប្បបរមា ១៤ (ដប់បួន) ថ្ងៃ អាចនឹង រឹតតែធ្ងន់ធ្ងរ ក្នុងករណីប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុងដែលមានលក្ខណៈស្រាលៗ។ ប្រធាន ពន្ធនាគារ គួរតែពិចារណា ដើម្បីរកភាពអាចបត់បែនច្រើនទៀត ក្នុងការគ្រប់គ្រងបទបញ្ជាផ្ទៃ ក្នុង។

ជាចុងបញ្ចប់ ក្រៅពីមាត្រានេះ ច្បាប់ពន្ធនាគារទាំងមូល គឺស្រពិចស្រពិលយ៉ាងខ្លាំង។ ច្បាប់នេះ មិនបញ្ជាក់ច្បាស់ពីគោលការណ៍សំខាន់ៗនៃបទបញ្ជាផ្ទៃក្នុង និងមិនមានតម្រូវការ ណា ដែលអគ្គនាយកដ្ឋានពន្ធនាគារ ឬ ក្រសួងមហាផ្ទៃ បង្កើតនីតិវិធីលម្អិតអំពីបទបញ្ជាផ្ទៃ ក្នុង។ នេះ គឺជាការមើលរំលងមួយដ៏ធ្ងន់ធ្ងរ។ ប្រព័ន្ធគ្រប់គ្រងពន្ធនាគារត្រូវការច្បាប់ និងវិធី

សាស្រ្ត សម្រាប់ការអនុវត្ត។ សំខាន់ណាស់ដែលច្បាប់ និងវិធីសាស្រ្តទាំងនេះ ត្រូវតែមានតម្លាភាព និងមានលក្ខណៈជាប្រព័ន្ធ។ ការបង្កើតប្រព័ន្ធបទបញ្ជាផ្ទៃក្នុងឲ្យបានគ្រប់គ្រាន់ គឺជាផ្នែកមួយនៃផែនការ ដែលអាចឲ្យពន្ធនាគារអនុវត្តតាមបទដ្ឋានសិទ្ធិមនុស្ស និងក្បួនច្បាប់។

➢ **អនុសាសន៍:** ច្បាប់នេះគួរតែមានការកែប្រែ ដោយដកចេញនូវបទល្មើសនៃការទទួលទណ្ឌកម្ម ចំពោះអំពើល្មើសនឹងបទបញ្ជាផ្ទៃក្នុងជាពិសេសការបង្ខាំងទុក និងការឃុំឃាំងឲ្យនៅដោយដាច់ឡែក។ ជំនួសឲ្យការដាក់ចេញនូវភាពចាំបាច់ជាវិជ្ជមាន សម្រាប់អំពើល្មើសច្បាប់នេះគួររឹតបន្តឹង ចំពោះការដាក់ទណ្ឌកម្មជាក់លាក់។ ការដាក់ទណ្ឌកម្មជាក់លាក់ អាចត្រូវបានប្រកាសឲ្យដឹងក្នុងបទបញ្ជាបន្ទាប់បន្សំ។

គោលការណ៍សំខាន់ៗគួរបញ្ជាក់ឲ្យបានច្បាស់ ដូចជាត្រូវការតាមដានដំណើរនៃការដាក់ទណ្ឌកម្មលើជនជាប់ឃុំ លទ្ធភាពនៃការប្តឹងតវ៉ាចំពោះអំពើល្មើសនឹងបទបញ្ជាផ្ទៃក្នុង និងតម្រូវការនៃ សមាមាត្រនឹងការដាក់ទណ្ឌកម្មចំពោះអំពើល្មើស។

ជាទីបញ្ចប់ ច្បាប់នេះគួរអំពាវនាវឲ្យមានការអនុម័តច្បាប់ដែលមានសេចក្តីលម្អិត គ្រប់គ្រងលើប្រព័ន្ធនៃបទបញ្ជាពន្ធនាគារ។ ច្បាប់ទាំងនេះ គួរបញ្ចូលខ្លឹមសារផ្សេងទៀត ដូចជា៖ តារាងនៃអំពើដែល ចាត់ទុកជាអំពើល្មើសដែលអាចដាក់ទណ្ឌកម្មបាន តារាងនៃទណ្ឌកម្មដែលអនុញ្ញាត ដោយភ្ជាប់ទៅនឹងប្រភេទនៃអំពើល្មើសជាក់លាក់ បទល្មើសដែលបានស៊ើបអង្កេត និងបានដោះស្រាយភ្លាមៗ និងដំណើរ ការនៃការការពារ រួមទាំងសិទ្ធិនៃការទទួលបានព័ត៌មានស្តីពី បទបញ្ជាផ្ទៃក្នុង និងការប្តឹងតវ៉ា។

## មាត្រា ៥៦

*មន្ត្រីស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងដែលមានបំណងចូលជួបសួរសុខទុក្ខជនជាប់ឃុំ ជាពលរដ្ឋខ្មែរ ឬពលរដ្ឋដែលខ្លួនធ្វើជាតំណាង ត្រូវជូនដំណឹងជាមុនទៅអគ្គនាយកដ្ឋានពន្ធនាគារ។ គ្រួសារ សាច់ញាតិ ឬមិត្តរបស់ជនបរទេស ដែលមានបំណងចូលជួបសួរសុខទុក្ខជនជាប់ឃាំង ត្រូវស្នើរមកអគ្គនាយកដ្ឋានពន្ធនាគារ តាមរយៈស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន។*

➢ **សេចក្តីអត្ថាធិប្បាយ១៖** មន្ត្រីស្ថានទូត និងស្ថានកុងស៊ុល ជាធម្មតាអាចជូនដំណឹងទៅពន្ធនាគារ មុននឹងការចូលជួបសួរសុខទុក្ខ ចន្លោះពេលនោះក៏អាចមានការប្រែប្រួលក្នុងករណីស្ថានភាពបន្ទាន់ ផងដែរ។ ការបង្កើតឲ្យមានឧបសគ្គសម្រាប់ជនបរទេសគឺរំលោភលើមាត្រា ៣៦ (១) (គ) នៃសន្ធិសញ្ញា ស្តីពីទំនាក់ទំនងកុងស៊ុល នៅវៀអែណា (Vienna Convention on

Consular Relations) ដែលសន្ធិសញ្ញានេះ ផ្តល់ឲ្យមន្ត្រីស្ថានកុងស៊ុល នូវសិទ្ធិពិសេសចូលជួបសួរសុខទុក្ខជនជាតិខ្លួនក្នុងពន្ធនាគារ។

➤ **សេចក្តីអត្ថាធិប្បាយ២៖** កថាខ័ណ្ឌទីពីរនៃមាត្រា ៥៦ បង្កើតឲ្យមានឧបសគ្គច្រើនបន្ថែមទៀត សម្រាប់ជនបរទេស ដែលមានបំណងទទួលអ្នកចូលជួបសួរសុខទុក្ខក្នុងពន្ធនាគារ។ កថាខ័ណ្ឌនេះ តម្រូវឲ្យពួកគេរៀបចំការចូលជួបសួរសុខទុក្ខតាមរយៈស្ថានទូតរបស់ខ្លួន តំណាងកុងស៊ុល ឬ មន្ត្រីទាំងនេះ ហាក់បីដូចជាជំទាស់នឹងការបង្ហាញខ្លួនរបស់ពួកគេនៅពន្ធនាគារ ដែលពួកគេ គួរតែអាចចូលបានជាធម្មតាដូចជាប្រពលរដ្ឋខ្មែរដែរ។ ទន្ទឹមនឹងនេះដែរមិនគួរតម្រូវអោយគ្រប់ភ្ញៀវបរទេសទាំងអស់ ត្រូវឆ្លងកាត់តាមរយៈបណ្តាញទូតទេ ទោះបីជាមានការតម្រូវចំពោះការចូលសួរសុខទុក្ខជាផ្លូវការណ៍ ពីតំណាងទូត ដែលមានពាំនាំមកជាមួយនូវជំនួយក៏ដោយ។ ជាពិសេស ការទាមទារនេះ គឺជាបន្ទុកសម្រាប់ប្រជាពលរដ្ឋនៃប្រទេសជាច្រើន ដែលជាតំណាងទូតនៅក្នុងប្រទេសកម្ពុជា។

➤ **អនុសាសន៍:** ច្បាប់នេះគួរតែមានការកែប្រែ ដោយដកចេញនូវរបាំងចំពោះការចូលជួបសួរសុខទុក្ខ សម្រាប់តំណាងទូត។ ច្បាប់នេះក៏គួរតែមានការកែប្រែផងដែរ ដោយដកចេញនូវការទាមទារឲ្យសាច់ញាតិ និងមិត្តភក្តិនៃជនបរទេស រៀបចំការចូលជួបសួរសុខទុក្ខ តាមរយៈតំណាងទូត។

## មាត្រា ៥៩

*បើអ្នកសួរសុខទុក្ខផ្លូវការ មានបំណងធ្វើទស្សនកិច្ចពន្ធនាគារណាមួយ ត្រូវផ្តល់ដំណឹងជាមុន ទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អំពីគោលបំណង និងសំណូមពរនៃទស្សនកិច្ចនោះ។*

*លទ្ធផលនៃទស្សនកិច្ចខាងលើ ត្រូវផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឬ ដោយលាយលក្ខណ៍អក្សរទៅប្រធានពន្ធនាគារ និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ។ ព័ត៌មាននោះត្រូវចាត់ទុកជាព័ត៌មានសម្ងាត់ លើកលែងតែមានការឯកភាពពីក្រសួងមហាផ្ទៃ។*

➤ **សេចក្តីអត្ថាធិប្បាយ:** អ្នកសួរសុខទុក្ខជាផ្លូវការមានកំណត់ក្នុងមាត្រា ៩ ដើម្បីបញ្ចូលអង្គការឃ្លាំមើលពន្ធនាគារដូចជា ការិយាល័យស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស អង្គការលីកាដូ និងសមាគមអាដហុក។ មាត្រា ៥៩ ចែងថា អង្គការទាំងនេះមិនត្រូវធ្វើរបាយការណ៍ អំពីការរកឃើញរបស់ខ្លួនក្នុងពន្ធនាគារដោយគ្មានការយល់ព្រមមុនពីក្រសួងមហាផ្ទៃ។ ខចែងនេះ គឺជាការបោសសម្អាតយ៉ាងច្បាស់ក្រឡែត ទៅលើអង្គការទាំងឡាយណាដែលធ្វើការតស៊ូមតិ ជាសាធារណៈអំពីបញ្ហាពន្ធនាគារ។ ជាពិសេស មាត្រានេះបានហាមឃាត់

មិនឲ្យមានការតស៊ូមតិ ក្នុងករណីអង្គការទាំងនោះ ស្រង់បានព័ត៌មាន ដែលបានប្រមូលពីការទស្សនៈកិច្ចពន្ធនាគារ ណាមួយ។

➢ **អនុសាសន៍:** មាត្រា ៥៩ គួរតែមានការកែប្រែ ដោយដកចេញនូវការទាមទារចំពោះព័ត៌មាន ដែលទទួលបានពីអ្នកចូលជួបសួរសុខទុក្ខផ្លូវការ ត្រូវរក្សាទុកជាការសម្ងាត់។ អង្គការឃ្លាំមើលពន្ធនាគារ ជាភាគីទីបី ដែលស្ទើរតែជាប្រភពតែមួយគត់ ផ្តល់ព័ត៌មានជាសាធារណៈ អំពីស្ថានភាពពន្ធនាគារ ក្នុងប្រទេសកម្ពុជា។ វាមានសារៈសំខាន់ដែលសាធារណៈជនអាចទទួលបានព័ត៌មានអំពីពន្ធនាគារ ពីភាគី ទីបី។ ការឃ្លាំមើល និងការតស៊ូមតិនៃក្រុមអ្នកឯករាជ្យ គឺមានសារៈសំខាន់ ដើម្បីធានាឲ្យបានថាសិទ្ធិ មនុស្សរបស់ជនជាប់ឃុំទទួលបានការការពារ និងធានាផងដែរថា ស្ថានភាពពន្ធាគារ ទទួលបាននូវភាពកែលំអ។ ជាងនេះទៀត លីកាដូមានជំនឿថា ប្រសិនបើអ្នកទោសម្នាក់រាយការណ៍ អំពីការរំលោភបំពាន ជូនដល់អ្នកធ្វើទស្សនៈកិច្ចផ្លូវការណ៍ វាគួរតែជាជម្រើសរបស់ជនជាប់ឃុំទៅវិញទេ ថាតើព័ត៌មាន នោះត្រូវរក្សាការសម្ងាត់ ឬ មិនចាំបាច់។

## មាត្រា ៧១

*បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ មានសិទ្ធិចុះកិច្ចសន្យាជាមួយរូបវន្តបុគ្គល ឬ នីតិបុគ្គល ឬ អង្គការជាតិ អន្តរជាតិ ដើម្បីបង្កើតការងារសម្រាប់កម្មវិធី ឧស្សាហាកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ និងមានសិទ្ធិចុះកិច្ចសន្យាលក់ផលិតផលឧស្សាហាកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ។*

➢ **សេចក្តីអត្ថាធិប្បាយ:** លីកាដូគាំទ្រចំពោះការបង្កើតការងារ និងកម្មវិធីបណ្តុះបណ្តាលសម្រាប់ជនជាប់ឃុំ ប៉ុន្តែមាត្រា ៧១ គឺមិនសមស្រប ពីព្រោះមាត្រានេះអនុញ្ញាតិឲ្យមានការលក់កម្លាំងពលកម្មរបស់ជនជាប់ឃុំ ទៅអោយក្រុមហ៊ុនឯកជន។ នេះគឺប្រឆាំងនឹងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ។

មាត្រា ១៥ នៃច្បាប់ការងាររបស់ប្រទេសកម្ពុជា (១៩៩៧) ចែងថា ការងារដោយបង្ខំ ឬ ជាកាតព្វកិច្ច ត្រូវហាមឃាត់ដាច់ខាត ដោយអនុឡោមតាមអនុសញ្ញា លេខ ២៩ ស្តីពីការងារដោយបង្ខំ ឬ កាតព្វកិច្ច។ អនុសញ្ញារបស់អង្គការការងារអន្តរជាតិលេខ ២៩ ហាមឃាត់ការប្រើប្រាស់កម្លាំងពលកម្មក្នុងពន្ធនាគារសម្រាប់ជាប្រយោជន៍រូបវន្តបុគ្គលឯកជនគ្រប់រូបភាព[៤]។ បទ

[៤] អនុសញ្ញាអង្គការការងារអន្តរជាតិលេខ ២៩ ស្តីពីការងារដោយបង្ខំ ឬជាកាតព្វកិច្ច (អនុម័តនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៣០ ហើយព្រះរាជាណាចក្រកម្ពុជាបានឲ្យសច្ចាប័ននៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩)

បញ្ញត្តិពន្ធនាគារកម្ពុជានាពេលថ្មីៗនេះ ចែងថា "ជនជាប់ឃុំមិនត្រូវតម្រូវឲ្យធ្វើការសម្រាប់ជាប្រយោជន៍ឯកជនឡើយ"[៥]។

ការអនុញ្ញាតិឲ្យមានការងារក្នុងពន្ធនាគារសម្រាប់ក្រុមហ៊ុនឯកជន ក្នុងមាត្រា ៧១ ជាក់ស្តែង គឺមិនអាចចាត់ទុកថា អាចស្ទង់បាននូវព័ត៌មានសម្ងាត់ថ្មីៗ ក្នុងប្រព័ន្ធផ្សាយព័ត៌មាន ដែលថា ពន្ធនាគារនៅប្រទេសកម្ពុជា ពីមុនមានរោងចក្រកាត់ដេរ ដែលគេសង្ស័យថា បានលក់សម្លៀកបំពាក់ទៅឲ្យអ្នកបញ្ជាទិញនៅក្រៅប្រទេស[៦]។ ក្នុងសន្និសិទស្តីពី សម្លៀកបំពាក់អន្តរជាតិ រៀបចំឡើងក្នុងរាជធានីភ្នំពេញ លោក ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានសារភាពថា "មានសម្លៀកបំពាក់មួយចំនួនកំពុងផលិតក្នុងពន្ធនាគារ" ប៉ុន្តែបញ្ហានេះ គឺមានតាំងពី "អតីតកាល វាមិនមានទៀតទេពេលនេះ"[៧]។

លោក ប្រសិទ្ធ បន្តមានប្រសាសន៍ថា ការរៀបចំបែបនេះ"អាចបង្កឲ្យមានគ្រោះមហន្តរាយ ក្នុងវិស័យឧស្សាហកម្មកាត់ដេរទាំងមូល "ដែលអាចបណ្តាលឲ្យអ្នកបញ្ជាទិញអន្តរជាតិ អាចរត់ចេញពីប្រទេសកម្ពុជា។ នេះអាចយល់បានថា ការនាំចូលទំនិញដែលផលិតក្នុងពន្ធនាគារ គឺមិនស្របនឹងច្បាប់ក្នុងប្រទេសមួយចំនួនដូចជា សហរដ្ឋអាមេរិកជាដើម[៨]។

➢ **អនុសាសន៍:** ការបង្កើតពន្ធនាគារឲ្យមានវិស័យការងារឯកជនកំពុងតែដើរលើបន្ទាត់មួយ យ៉ាងគ្រោះថ្នាក់ មិនមែនសម្រាប់តែជនជាប់ឃុំប៉ុណ្ណោះទេ ប៉ុន្តែទាំងវិស័យឧស្សាហកម្មកាត់ដេរកម្ពុជា ទាំងមូល។ លីកាដូ សូមផ្តល់អនុសាសន៍ ដល់រដ្ឋសភាជាតិគួរលុបបំបាត់ចោលខចែងណាក្នុងច្បាប់ពន្ធនាគារ ដែលអនុញ្ញាតិឲ្យមានការប្រើប្រាស់កម្លាំងពលកម្ម ក្នុងពន្ធនាគារបម្រើឲ្យប្រយោជន៍ឯកជន។ ជំនួសមកវិញ កម្មវិធីការងារពន្ធនាគារ គួរចាត់ចែងការងារវិស័យសាធារណៈ ឬ ផ្តោតលើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។

□□□

---

[៥] នីតិវិធីពន្ធនាគារលេខ ១១ និង ៣, ៤ (ឆ្នាំ២០០៣)

[៦] អាប៊ី សេហ្វ, "មន្ត្រីរដ្ឋាភិបាលបាននាំយកអ្នកទោសមៅការរោងចក្រកាត់ដេរខុសច្បាប់ជាបន្តបន្ទាប់" កាសែតឌឹខេមបូឌាដេលី ចេញផ្សាយនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១១

[៧] អត្ថបទដដែល

[៨] សូមមើលច្បាប់បង់ពន្ធ ឆ្នាំ១៩៣០ ផ្នែក ៣០៧ (អនុម័តជាក្រមសហរដ្ឋអាមេរិក លេខ ១៩ វគ្គ ១៣០៧)